**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ការិយាល័យអ្នកនាំពាក្យ**

**លេខ ៣០៤ សប្រក**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី

## ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤

ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង:

**១_សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។**

**២_ផែនការសកម្មភាព ស្តីពីសុខដុមនីយកម្ម ឆ្នាំ ២០០៥_០៨ ដែលត្រូវដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកផ្តល់ជំនួយ (CG) ។**

**៣_របាយការណ៍លទ្ធផលប្រជុំក្រុមការងារលើកទី ៣ ស្តីពីការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា_ឡាវ_វៀតណាម ។**

**៤_បញ្ហាផ្សេងៗ : សេចក្តីរាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីឯកសារជំហររបស់រាជរដ្ឋាភិបាលសំរាប់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកផ្តល់ជំនួយ (CG) នៅថ្ងៃទី ០៦_០៧ ខែ ធ្នូ ឆ្នាំ ២០០៤**

ក្រោយពីបានពិភាក្សានិងផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសំរេច :

### I-អំពីសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

គណៈរដ្ឋមន្ត្រីបានឯកភាព និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំឡើង មានទិសដៅប្រមូលផ្តុំសំរេចអោយបាននូវគោលដៅសំខាន់ៗ ដូចតទៅ :

-បំរើអោយការបន្តកំណែទំរង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាលគ្រប់មុខសញ្ញា

-សំរេចចក្ខុវិស័យនៃកំណើនពី ៦% ទៅ ៧% ក្នុងមួយឆ្នាំ និងជំរុញអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ ឆ្នាំ លើកទី ២ (២០០១-២០០៥) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ **(NPRS)** និងអភិវឌ្ឍន៍កម្មវិធីវិនិយោគសាធារណៈ **(PIP)** រំកិលបីឆ្នាំ

-បំរើអោយការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការធានានូវតុល្យភាពថវិកា និងទប់ស្កាត់អតិផរណាអោយស្ថិតនៅក្រោម ៥%

-ធានាការពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុក្រុមប្រឹក្សា ឃុំ-សង្កាត់ សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន

-បំរើអោយការខិតខំស្រូបទាញវិនិយោគទុនពីក្រៅប្រទេស ទាំងជាជំនួយអភិវឌ្ឍន៍ផ្លូវការ **(ODA)** ទាំងជាទុនវិនិយោគផ្ទាល់ពីបរទេស **(FDI)** និងបំរើអោយការជំរុញជីវភាពធុរកិច្ចក្នុងប្រទេស ។

## II-អំពីផែនការសកម្មភាព ស្ដីពីសុខដុមនីយកម្ម ឆ្នាំ ២០០៥-០៨ ដែលត្រូវដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកផ្ដល់ជំនួយ (CG)

គណៈរដ្ឋមន្ត្រីបានឯកភាព និងអនុម័តផងដែរទៅលើផែនការសកម្មភាព ស្ដីពីសុខដុមនីយកម្ម ឆ្នាំ ២០០៥-០៨ ដែលខ្លឹមសារសង្ខេបសំខាន់ៗ មាន :

***ផ្នែក A - ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំ :***

១-រាជរដ្ឋាភិបាលដឹកនាំដំណើរការ និងរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិតែមួយ សំរាប់រយៈពេល ៥ ឆ្នាំ (២០០៦-២០១០)

២-រាជរដ្ឋាភិបាលដឹកនាំការសំរបសំរួលជំនួយអភិវឌ្ឍន៍ផ្លូវការ

៣-កម្ពុជាដើរតួនាទីយ៉ាងសកម្ម ក្នុងការអនុវត្តសេចក្ដីប្រកាសទីក្រុងរ៉ូមស្ដីពីសុខដុមនីយកម្ម (២០០៣) ក្នុងចំណោមប្រទេសសាកល្បង ១៤

***ផ្នែក B - ការអភិវឌ្ឍន៍សមត្ថភាព :***

សមត្ថភាពរបស់រាជរដ្ឋាភិបាលត្រូវបានពង្រឹងសំរាប់គ្រប់គ្រង និងសំរបសំរួលជំនួយប្រកបដោយប្រសិទ្ធភាព

***ផ្នែក C - ភាពរលូន និងស៊ីសង្វាក់ :***

១-រាជរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយអនុម័តផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រ សំរាប់ក្របខ័ណ្ឌរួមក្នុងការរៀបចំផែនការជំនួយអភិវឌ្ឍន៍

២-ការអនុវត្តរបស់អ្នកផ្ដល់ជំនួយត្រូវស៊ីសង្វាក់គ្នានឹងសមាសធាតុនៃខួបកម្មវិធី/គំរោង

៣-អ្នកផ្ដល់ជំនួយបង្កើនការប្រើប្រាស់ជាបណ្ដើរៗ នូវនីតិវិធី ប្រព័ន្ធ និងទំរង់ការអនុវត្តរបស់រាជរដ្ឋាភិបាលតាមពេលវេលាសមស្រប

***ផ្នែក D - សុខដុមនីយកម្ម :***

គឺការជំរុញអោយដៃគូអភិវឌ្ឍន៍ផ្ដល់ជំនួយអោយស្របនឹងតំរូវការអាទិភាពរបស់រាជរដ្ឋាភិបាល ។ ក្នុងក៏រិតរៀបចំយុទ្ធសាស្ត្រផ្ដល់ជំនួយ ត្រូវផ្អែកតាមឯកសារជាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល បច្ចុប្បន្ននេះគឺយុទ្ធសាស្ត្រចតុកោណ ។ រីឯការអនុវត្តន៍គំរោង/កម្មវិធី និងការត្រួតពិនិត្យ តាមដានប្រសិទ្ធភាពនៃជំនួយវិញ

ក៏លើកទឹកចិត្តអោយអ្នលផ្តល់ជំនួយប្រើប្រាស់ប្រព័ន្ធ និងទំរង់ការរបស់រាជរដ្ឋាភិបាលផងដែរ ។ ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម បានបង្ហាញពីភាពចាំបាច់ក្នុងការបង្កើតនូវក្រុមការងារបច្ចេកទេសចំរុះ **(Joint Technical Working Group)** រវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ស្តីពីការរៀបចំផែនការ និងត្រួតពិនិត្យភាពក្រីក្រ **(Planning and Poverty Monitoring)** បន្ថែមលើក្រុមការងារចំរុះដែលមានស្រាប់ទាំង ១៧ ក្រុម ។

## III-អំពីរបាយការណ៍ស្តីពីលទ្ធផលប្រជុំក្រុមការងារលើកទី ៣ ស្តីពីការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម

គណៈរដ្ឋមន្ត្រីបានឯកភាព និងអនុម័តលើរបាយការណ៍លទ្ធផលប្រជុំក្រុមការងារលើកទី ៣ ស្តីពីការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម ដែលលទ្ធផលសំខាន់ៗនៃកិច្ចប្រជុំគឺ :

-ឯកភាពលើខ្លឹមសារនៃឯកសារពីរគឺ ផែនការមេសំរាប់អភិវឌ្ឍសេដ្ឋកិច្ចសង្គមតំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម និងសេចក្តីប្រកាសរួមសំរាប់បង្កើតកិច្ចសហប្រតិបត្តិការអភិវឌ្ឍតំបន់ត្រីកោណ ដែលត្រូវប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងចុះហត្ថលេខា

-ឯកភាពលើការដាក់បញ្ចូលខេត្តមណ្ឌលគីរីរបស់កម្ពុជា និងខេត្តសារ៉ាវ៉ាន់ របស់ប្រទេសឡាវ ទៅក្នុងតំបន់ត្រីកោណ ហើយបានកំណត់ថា ឯកសារមេនេះជាឯកសារចំហរ ដើម្បីទុកលទ្ធភាពសំរាប់ដាក់បញ្ចូលខេត្តដទៃទៀតនៅពេលក្រោយ

-ឯកភាពបង្កើតគណៈកម្មាធិការសំរបសំរួលថ្នាក់រដ្ឋមន្ត្រីរវាងប្រទេសទាំងបី ដើម្បីជំរុញការអនុវត្តផែនការមេអោយបានជោគជ័យ

-ឯកភាពស្នើអោយមានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងបី មុនកិច្ចប្រជុំកំពូល ដើម្បីពិនិត្យឯកសារចាំបាច់ រួចរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលនៃប្រទេសរៀងៗខ្លួន ។

## IV-អំពីបញ្ហាផ្សេងៗ

សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក៏បានណែនាំលើការអភិវឌ្ឍន៍នៅតំបន់ត្រីកោណ (កម្ពុជា-ឡាវ-វៀតណាម) អោយយកចិត្តទុកដាក់លើការអភិរក្សព្រៃឈើ និងសត្វព្រៃ ដើម្បីអោយតំបន់នេះក្លាយទៅជារមណីយដ្ឋានធម្មជាតិ ។ សម្តេចនាយករដ្ឋមន្ត្រីក៏បានណែនាំអោយក្រសួងសាធារណការ និងដឹកជញ្ជូន ជំរុញអោយភាគីក្រុមហ៊ុនវៀតណាមបើកការដ្ឋានសាងសង់ផ្លូវលេខ ៧៨ អោយបានឆាប់រហ័ស ។

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅម៉ោង ១២ និង ២០ នាទី ។

ភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ២០០៤